ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រស្ថិតិ
# សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៨


## អគ្គនាយកដ្ឋានគោលនយោបាយ
## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ខែមីនា ឆ្នាំ២០១៩

## មាតិកា


I. សេចក្តីអធិប្បាយសង្ខេប ........................................ ១

II. ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ........................................ ៤

១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ ........................................ ៤

២. សូចនាករតាមវិស័យ ........................................ ៥

២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ........................................ ៥

២.៣. អត្រាប្តូរប្រាក់ ........................................ ៦

២.៤. ហិរញ្ញវត្ថុសាធារណៈ ........................................ ៧

២.៥. ឥណទាន និងរូបិយវត្ថុ ........................................ ១០

២.៦. វិស័យពាណិជ្ជកម្ម ........................................ ១១

២.៧. ការវិនិយោគឯកជន ........................................ ១៤

២.៨. វិស័យទេសចរណ៍ ........................................ ១៥

២.៩. វិស័យសំណង់ ........................................ ១៦

៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ ........................................ ១៧

III. ឧបសម្ព័ន្ធ ........................................ ២០

# សេចក្តីអធិប្បាយសង្ខេប

ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈកម្ពុជា ក្នុងត្រីមាសទី៤ឆ្នាំ២០១៨ បានបន្តរឹងមាំ និងធន់នឹងវិបត្តិជាងបណ្តាត្រីមាសក្នុងឆ្នាំមុនៗ ទោះបីជាបានប្រឈមនឹងហានិភ័យមួយចំនួនក្តី។ អត្រាអតិផរណានិងប្តូរប្រាក់ ប្រែប្រួលក្នុងកម្រិតទាប ដែលអាចគ្រប់គ្រងបាន។ ស្ថានភាពចំណូលនិងចំណាយចរន្តដោយមានការគាំទ្រពីប្រសិទ្ធភាព នៃការកៀរគរចំណូល និងការធ្វើគោលនយោបាយសារពើពន្ធកម្ម បានបន្តភាពប្រសើរឡើង និងរក្សាបានលំនឹងអតិរេកចរន្ត។ ចំណែកផ្នែកលក់ដុំ-រាយ, កាត់ដេរ, ទេសចរណ៍ និងលំហូរវិនិយោគផ្ទាល់ពីបរទេស ជាពិសេសលើវិស័យអចលនទ្រព្យនិងធនាគារ បានបន្តកំណើនក្នុងអត្រាពីរខ្ទង់ក្នុងបរិយាកាសអំណោយផលនៃស្ថេរភាពនយោបាយក្នុងប្រទេស និងកំណើនសេដ្ឋកិច្ចពិភពលោក។

**កសិកម្ម** [1]

ស្ថានភាពកសិកម្ម ដោយមិនគិតពីការចិញ្ចឹមសត្វពាហនៈ រក្សាបានកំណើនល្អ ដែលបានឆ្លុះបញ្ចាំងពីភាពប្រសើរឡើងនៃ**បរិមាណផលស្រូវ** ៧,៤ លានតោន (+៣,៥%), **បរិមាណផលិតកៅស៊ូ (ក្រែប)** ប្រមាណ ២២០ពាន់តោន (+១៣,៩%), **ព្រមទាំងផ្នែកជលផល** ប្រមាណ ៩១០ ពាន់តោន (+៦,៣%)។ ទន្ទឹមនឹងកំណើនបរិមាណផលទាំងអស់នេះ ការជំរុញសហគ្រាសកែច្នៃផលិតផលកសិ- ឧស្សាហកម្ម គឺជាអាទិភាពចំពោះមុខ ដើម្បីរក្សាស្ថេរភាពថ្លៃដើមទី, ជំនួសការប្រើប្រាស់នៅសល់, តំណភ្ជាប់សហគ្រាសធុនតូច/មធ្យម និងពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចជាដើម ក្នុងរយៈពេលមធ្យមនិងវែង។

**ទេសចរណ៍** [2]

សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨ នេះ កម្ពុជាទទួលបានអ្នកដំណើរប្រមាណជា ១,៨ លាននាក់ (+៨,០%) ក្នុងនោះ ចំនួនភ្ញៀវចូលតាមព្រលានយន្តហោះអន្តរជាតិ មាន ១,១ លាននាក់ (+២២,៤%)។ កំណើនភ្ញៀវនេះ គឺមានការចូលរួមជាបន្តបន្ទាប់ពីការពង្រីកជើងហោះហើរត្រង់ទៅមក, ការពង្រីកវិសាលភាពអាកាសយានដ្ឋានជាបន្តបន្ទាប់, ការបង្កើនការផ្សព្វផ្សាយពីតំបន់សក្តានុពលទេសចរណ៍, ការធ្វើពិពិធកម្មទីផ្សារបន្ថែម និងជាពិសេសការរក្សាបានស្ថេរភាពនយោបាយក្នុងប្រទេស។

**សំណង់** [3]

សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨ ការផ្តល់លិខិតអនុញ្ញាតសាងសង់ទូទាំងប្រទេសមាន ៧៤៩ គម្រោង (-១៦,៤%), មានតម្លៃ ៩៣៥ លានដុល្លារ (-២៩,១%) និងលើក្រឡាផ្ទៃសំណង់

1 ប្រភពទិន្នន័យ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ទិន្នន័យ គិតត្រឹមខែធ្នូ ឆ្នាំ២០១៨។

2 ប្រភពទិន្នន័យ: ក្រសួងទេសចរណ៍

3 ប្រភពទិន្នន័យ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សរុប ១,៦ លាន ម៉ែត្រការ៉េ (-១៩,១%)។ ទន្ទឹមនឹងការធ្លាក់ចុះនៃគម្រោងអនុញ្ញាតសាងសង់ ការផ្តល់ឥណទានផ្នែកសំណង់និងអចលនទ្រព្យ បានថមថយពី ៣៧,៣% មកនៅ ២៩,៨%។

**ស្ថានភាពហិរញ្ញវត្ថុសាធារណៈ** [4]

យោងតាមទិន្នន័យបឋមពីអគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងត្រីមាសទី៤ ឆ្នាំ២០១៨ នេះ ការប្រមូលចំណូលចរន្តសរុបនៅរដ្ឋបាលថ្នាក់ជាតិអនុវត្តបានចំនួន ៥ ៥៤៤ ប៊ីលានរៀល ក្នុងនោះ ចំណូលសារពើពន្ធ អនុវត្តបាន ៤ ៥៩៩ ប៊ីលានរៀល (+២៥,១%) និងចំណូលមិនមែនសារពើពន្ធ ៩៤៥ ប៊ីលានរៀល (+៦%)។ ក្នុងន័យនេះ ចំណូលចរន្តសរុបត្រឹមដំណាច់ឆ្នាំ ២០១៨ សម្រេចបាន ១១២% នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ឬប្រមាណ ១៩,៧% នៃ ផ.ស.ស ឆ្នាំ២០១៨ (ប៉ាន់ស្មាន)។

**អតិផរណា និងអត្រាប្តូរប្រាក់** [5]

អតិផរណាក្នុងត្រីមាសទី៤ ឆ្នាំ២០១៨ ស្ថិតនៅក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ពោលគឺជាមធ្យមក្នុងអត្រា ២,៥% ទាបជាងត្រីមាសដូចគ្នាឆ្នាំ២០១៧ ដោយសារកំណើនចំណាយទាបនៃក្រុមអាហារ-ភេសជ្ជៈមិនមានជាតិស្រវឹង ២,៥% និងការដឹកជញ្ជូន ២,៩%។ ក្នុងរយៈពេលដូចគ្នានេះ អត្រាប្តូរប្រាក់មានស្ថិរភាពល្អ ពោលគឺជាមធ្យម ៤ ០៤៧ រៀល/ ដុល្លារអាមេរិក មានការប្រែប្រួលត្រឹម ០,២៥% ប៉ុណ្ណោះ។

**ប្រតិបត្តិការរូបិយវត្ថុ និងឥណទាន** [6]

អត្រារូបិយវត្ថុទូទៅធៀបនឹង ផ.ស.ស (ប៉ាន់ស្មាន) មានការរីកចម្រើនយ៉ាងឆាប់រហ័ស គិតត្រឹមត្រីមាសទី៤ នេះ ពោលគឺកើនពី ៧៩,១% ឆ្នាំ២០១៧ ទៅ ៨៩,០% ឆ្នាំ២០១៨។ កំណើនឥណទានសរុប បានកើនពី ២២,៧% ទៅ ២៤,៦% ក្នុងនោះ ឥណទានផ្តល់ទៅគ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ (+១៩,៦%), តម្រូវការផ្ទាល់ខ្លួន (+៤២,០%) និងឥណទានពី MFIs បានថមថយកំណើនពី ៣៦% មកនៅត្រឹមរង្វង់ ២៥%។ ជាការកត់សម្គាល់ ទំហំឥណទានក្នុងវិស័យសំណង់ (*) បានបន្តកំណើនខ្ពស់ក្នុងអត្រា ២៩,៨%។

**ពាណិជ្ជកម្មក្រៅប្រទេស** [7]

ការនាំចូលមុខទំនិញគ្រប់មុខ គិតរួមទាំងការនាំចូលជាបន្ទុករដ្ឋ)) នៅត្រីមាសទី៤ ឆ្នាំ២០១៨ មានទំហំ ១៧ ០២៣ ប៊ីលានរៀល (+២៣,២%) ធៀបនឹងឆ្នាំមុន ដោយសារកំណើនខ្ពស់លើផលិតផលនាំចូលចម្បង ដូចជា÷ បរិក្ខារសំណង់ (+៦៦,៨%), ប្រេងឥន្ធនៈ (+៧៧,៩%), ទោចក្រយានយន្ត (+៣១,៥%) ព្រមទាំងវាយនភ័ណ្ឌនិងសម្លៀកបំពាក់ (+៤,៤%)។

[4] ទិន្នន័យបណ្តោះអាសន្នពីអគ្គនាយកដ្ឋានរតនាគារជាតិ។ ការអនុវត្តចំណាយសម្រាប់ដំណាច់ឆ្នាំ២០១៨ ពុំទាន់បានកត់ត្រាទាំងស្រុង។

[5] ប្រភពទិន្នន័យ: វិទ្យាស្ថានជាតិស្ថិតិ/ ក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា

[6] ប្រភពទិន្នន័យ: ធនាគារជាតិនៃកម្ពុជា

(*) និយមន័យ÷ ឥណទានសំណង់, ការជួញដូរអចលនទ្រព្យ និងកម្ចីទិញផ្ទះជាកម្មសិទ្ធផ្ទាល់ខ្លួន ព្រមទាំងឥណទានពី MFIs សម្រាប់សំណង់

[7] ប្រភពទិន្នន័យ: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា/ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទិន្នន័យនាំចេញ-នាំចូល នឹងមានការកែសម្រួល។

ការនាំចេញសរុបរបស់កម្ពុជា នៅត្រីមាសទី៤ ឆ្នាំ២០១៨ មានទំហំ ១២ ៥៣៩ ប៊ីលានរៀល ក្នុងអត្រាកំណើនទាប (+៧,៨%) ក្នុងនោះ ការនាំចេញផលិតផលកាត់ដេរនិងស្បែកជើង (+១៥,៤%) និងកសិកម្ម(+១២,៦%) ខណៈផលិតផលគ្រឿងបង្គុំ(-៤៤,៨%), ផលិតផលឧស្សាហកម្មផ្សេងទៀត (-១៣,៤%) និងកង់ (-៣,០%)។ ការនាំចេញទៅទីផ្សារអាមេរិក មានស្ថានភាពប្រសើរខ្លាំង ក្នុងទឹកប្រាក់ ៧៦៣ លានដុល្លារ(+២៣,៩%) ក្នុងនោះ ផលិតផលកាត់ដេរនិងស្បែកជើង (+៣២,២%)។ **ឧស្សាហកម្មនាំចេញផលិតផលកាត់ដេរនិងស្បែកជើងរបស់កម្ពុជា ទទួលបានអត្ថប្រយោជន៍ជាច្រើន អំឡុងពេលសង្គ្រាមពាណិជ្ជកម្ម។**

ផលិតផលនាំចេញទៅទីផ្សារអឺរ៉ុប (EU28) មានទំហំ ១ ១៤៥ លានដុល្លារ ក្នុងអត្រាកំណើនទាបប្រមាណ ២,៨% ក្នុងនោះ កំណើនពីកាត់ដេរនិងស្បែកជើង មានអត្រា ២,៧% ប៉ុណ្ណោះ រីឯផលិតផលអង្ករ មានកំណើននាំចេញប្រមាណ ៤៥,៦%។

**ការវិនិយោគឯកជន** [8]

គម្រោងវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេសដែលអនុម័តដោយ CDC នៅត្រីមាសទី៤ ឆ្នាំ២០១៨ មាន ៥៤ គម្រោង លើទុនវិនិយោគ ១ ៨៥០ លានដុល្លារ ខ្ពស់ជាងរយៈពេលដូចគ្នាឆ្នាំ២០១៧ ដែលមាន ២៥ គម្រោង និងទុនវិនិយោគ ប្រមាណ ១២០ លានដុល្លារ ប៉ុណ្ណោះ។ ការវិនិយោគលើវិស័យសេវាកម្មនិងទេសចរណ៍ និងឧស្សាហកម្ម មានចំណែកប្រមាណ ៨០% និង ១៥,៧% នៃការវិនិយោគសរុប។

[8] ប្រភពទិន្នន័យៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ

*តារាង 1 ÷ ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ*

| | ឯកតា | ត្រីមាសទី៤ | | |
|---|---|---|---|---|
| | | ២០១៦ | ២០១៧ | ២០១៨ |
| **សូចនាករម៉ូលដ្ឋាន** | | | | |
| អតិផរណា (កំណើនប្រចាំឆ្នាំ) | % | 3.9% | 2.2% | 1.6% |
| អតិផរណា (កំណើនមធ្យមប្រចាំឆ្នាំ) | % | 2.9% | 3.0% | 2.5% |
| អត្រាប្តូរប្រាក់រៀល/ ដុល្លារ (មធ្យមប្រចាំឆ្នាំ) | រៀល | 4,042 | 4,037 | 4,047 |
| **ឥណទាន និងរូបិយវត្ថុ** | | | | |
| កំណើនរូបិយវត្ថុទូទៅ | % នៃ ផសស | 17.9% | 23.8% | 24.0% |
| អត្រារូបិយវត្ថុទូទៅ | % នៃ ផសស | 70.9% | 79.6% | 89.0% |
| កំណើនឥណទាន | % | 15.8% | 22.7% | 24.6% |
| **ពាណិជ្ជកម្មអន្តរជាតិ** | | | | |
| ទំហំពាណិជ្ជកម្មនាំចេញ | ប៊ីលានរៀល | 9,915 | 11,631 | 12,539 |
| ទំហំពាណិជ្ជកម្មនាំចូល | ប៊ីលានរៀល | (12,488) | (13,821) | (17,023) |
| **វិនិយោគឯកជន** | | | | |
| គម្រោង | ចំនួន | 28 | 25 | 54 |
| ទុនវិនិយោគ | លានដុល្លារ | 507 | 120 | 1,850 |
| បង្កើតការងារ | ពាន់នាក់ | 26,692 | 21,220 | 45,940 |
| **ទេសចរណ៍** | | | | |
| អ្នកធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជា | នាក់ | 1,503 | 1,689 | 1,825 |
| **វិស័យសំណង់** | | | | |
| គម្រោង | ចំនួន | 627 | 896 | 749 |
| ក្រឡាផ្ទៃ | ម២ | 2,351 | 2,238 | 1,587 |
| តម្លៃសាងសង់ | លានដុល្លារ | 974 | 1,163 | 935 |
| **ថ្លៃទំនិញលើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក) [9]** | | | | |
| អង្ករ | ដុល្លារ/តោន | 340 | 379 | 401 |
| ប្រេងឆៅ (Brent) -- បារ៉ែល | ដុល្លារ/បារ៉ែល | 46 | 63 | 65 |
| កៅស៊ូ | ដុល្លារ/តោន | 1,871 | 1,569 | 1,353 |

ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, និងធនាគារជាតិ

[9] គឺជាថ្លៃទំនិញចុងត្រីមាស

*រូបភាព 1 ÷ ស្ថានភាពសូចនាករសេដ្ឋកិច្ចសំខាន់ៗ*




ប្រភពៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, និងធនាគារជាតិ

## ២. សូចនាករតាមវិស័យ

### ២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

*តារាង 2 ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យមប្រចាំត្រីមាសទី៤) -- ឆ្នាំ២០១៨*

| សូចនាករ | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **មុខទំនិញគ្រប់មុខ** | **164.6** | **169.6** | **174.0** |
| អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 199.0 | 206.4 | 211.8 |
| ភេសជ្ជៈមានជាតិស្រវឹង និង ថ្នាំជក់ | 156.0 | 159.7 | 162.7 |
| សម្លៀកបំពាក់ និង ស្បែកជើង | 140.2 | 144.4 | 147.7 |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 124.4 | 124.4 | 126.1 |
| គ្រឿងសង្ហារឹម សម្ភារប្រើប្រាស់ និងការថែទាំ | 147.9 | 150.1 | 150.7 |
| សុខាភិបាល | 131.2 | 133.2 | 135.4 |
| ការដឹកជញ្ជូន | 108.9 | 112.8 | 116.5 |
| គមនាគមន៍ | 68.3 | 68.1 | 67.6 |
| ការកំសាន្ត និងវប្បធម៌ | 117.3 | 118.8 | 118.4 |
| ការសិក្សា | 160.1 | 159.9 | 159.6 |
| ភោជនីយដ្ឋាន | 239.6 | 253.2 | 269.8 |
| ទំនិញ និង សេវាកម្មផ្សេងៗ | 139.0 | 140.6 | 144.8 |

ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

*រូបភាព 2÷ ស្ថានភាពអតិផរណា (មធ្យមប្រចាំត្រីមាស)*




ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

## ២.៣. អត្រាប្តូរប្រាក់

*តារាង 3÷ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស) -- ឆ្នាំ២០១៨*

| អត្រាប្តូរប្រាក់ចុងខែ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| 2011 | 4,043 | 4,045 | 4,095 | 4,065 |
| 2012 | 4,030 | 4,038 | 4,056 | 4,007 |
| 2013 | 3,995 | 4,032 | 4,062 | 4,020 |
| 2014 | 3,994 | 4,026 | 4,060 | 4,070 |
| 2015 | 4,043 | 4,056 | 4,092 | 4,051 |
| 2016 | 4,023 | 4,055 | 4,094 | 4,042 |
| 2017 | 4,016 | 4,047 | 4,080 | 4,037 |
| 2018 | 4,012 | 4,046 | 4,073 | 4,047 |

ប្រភព: ធនាគារជាតិនៃកម្ពុជា

*រូបភាព 3÷ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស) -- ឆ្នាំ២០១៨*




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៤. ហិរញ្ញវត្ថុសាធារណៈ:

*តារាង 4÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកចំណូល*

| ប៊ីលានរៀល | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **I. ចំណូលក្នុងប្រទេស** | **3,600** | **4,629** | **5,635** |
| **១. ចំណូលចរន្ត** | **3,551** | **4,568** | **5,544** |
| ***ក. ចំណូលសារពើពន្ធ*** | **2,724** | **3,677** | **4,599** |
| **១. ពន្ធផ្ទាល់** | **496** | **651** | **825** |
| ពន្ធលើប្រាក់បៀវត្ស | 124 | 173 | 166 |
| ពន្ធលើប្រាក់ចំណេញ | 317 | 407 | 658 |
| ពន្ធលើផលទុនដីធ្លី និងផ្ទះសំបែង | 55 | 71 | 0 |
| **២. ពន្ធប្រយោល** | **1,744** | **2,454** | **3,078** |
| ពន្ធលើផលរបរ | 0 | 0 | 0 |
| អាករលើតម្លៃបន្ថែម | 1,053 | 1,322 | 1,618 |
| អាករពិសេស | 668 | 1,074 | 1,407 |
| ចំណូលពន្ធផ្សេងៗទៀត | 23 | 58 | 52 |

| ប៊ីលានរៀល | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **៣. ពន្ធពាណិជ្ជកម្មក្រៅប្រទេស** | **484** | **572** | **695** |
| ពន្ធនាំចូល | 476 | 557 | 680 |
| ពន្ធនាំចេញ | 9 | 15 | 16 |
| ពន្ធនាំចេញផ្សេងៗទៀត | 0 | 0 | 0 |
| ***ខ. ចំណូលមិនមែនសារពើពន្ធ*** | **827** | **891** | **945** |
| ចំណូលពីនេសាទ | 0 | 0 | 0 |
| ចំណូលពីព្រៃឈើ | 5 | 9 | 3 |
| ចំណូលពីការជួលសហគ្រាស | 2 | 1 | 8 |
| ចំណូលពីអាកាសចរស៊ីវិល | 43 | 41 | 34 |
| ចំណូលពីសម្បទាន | 87 | 122 | 127 |
| ចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 86 | 74 | 67 |
| អាករស្ថានទូត (ចំណូលពីលិខិតឆ្លងដែន និងទិដ្ឋាការ) | 139 | 170 | 0 |
| ផលពីការបង់សិទ្ធិប្រលង | 76 | 66 | 0 |
| ចំណូលពីការជួល | 6 | 5 | 0 |
| ចំណូលមិនមែនពន្ធផ្សេងៗ | 383 | 403 | 705 |
| **២. ចំណូលមូលធន** | **50** | **61** | **91** |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *តារាង 5 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកចំណាយ*

| ប៊ីលានរៀល | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **II. ចំណាយសរុប** | **5,978** | **7,146** | **4,876** |
| **១. ចំណាយចរន្ត** | **4,170** | **4,923** | **3,455** |
| ***ក. ការពារ និងសន្តិសុខជាតិ*** | **893** | **1,088** | **938** |
| ***ខ. រដ្ឋបាលស៊ីវិល*** | **3,228** | **3,791** | **2,486** |
| ***គ. ចំណាយការប្រាក់*** | **49** | **43** | **31** |
| **២. ចំណាយមូលធន** | **1,808** | **2,223** | **1,421** |
| ហិរញ្ញប្បទានក្នុងស្រុក | 750 | 1,062 | 702 |
| ពីចំណូលក្នុងស្រុក | 463 | 1,062 | 702 |
| ពីជំនួយជាទំនិញ | 287 | 0 | 0 |
| ហិរញ្ញប្បទានពីបរទេស | 1,058 | 1,161 | 719 |
| ***និទភាពចរន្ត (សាច់ប្រាក់)*** | **(457)** | **(333)** | **2,088** |
| ***និទភាពទូទៅ (សាច់ប្រាក់)*** | **(2,215)** | **(2,495)** | **758** |

## *តារាង 6 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកហិរញ្ញប្បទាន*

| ប៊ីលានរៀល | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **III. ហិរញ្ញប្បទាន** | **2,215** | **2,495** | (758) |
| **១. ហិរញ្ញប្បទានពីបរទេស** | **1,186** | **1,021** | **666** |
| ទ្រទ្រង់ថវិកា | 287 | 0 | 0 |
| ជំនួយគម្រោងអភិវឌ្ឍន៍ | 1,024 | 1,195 | 757 |
| រំលស់បំណុលបរទេស | (125) | (174) | (92) |
| **២. ហិរញ្ញប្បទានក្នុងស្រុក** | **466** | **38** | **67** |
| បញ្ញើរដ្ឋាភិបាល | (60) | (301) | (1,253) |
| វិស័យឯកជន | 537 | (27) | 0 |
| ផ្សេងៗ | (12) | 366 | 0 |
| **៣. ប្រតិបត្តិការកំពុងដំណើរការ** | **563** | **1,436** | **(1,459)** |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *រូបភាព 4 ÷ ស្ថានភាពតុល្យភាពថវិកាចរន្ត (គិតជាប៊ីលានរៀល)*




ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៥. ឥណទាន និងរូបិយវត្ថុ

*តារាង 7៖ ស្ថានភាពរូបិយវត្ថុ*

| (ប៊ីលានរៀល) | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **31,814** | **42,575** | **55,214** |
| ទ្រព្យសកម្មបរទេស | 47,581 | 60,893 | 73,649 |
| ទ្រព្យអកម្មបរទេស | (15,767) | (18,318) | (18,435) |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **25,802** | **28,744** | **33,229** |
| ឥណទានក្នុងស្រុក | 48,310 | 55,856 | 67,616 |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | (8,148) | (11,067) | (14,804) |
| ផ្នែកមិនមែនរដ្ឋាភិបាល | 56,459 | 66,923 | 82,420 |
| **ទ្រព្យសកម្មផ្នែកផ្សេងៗ** | **(22,508)** | **(27,113)** | **(34,387)** |
| ប្រាក់បញ្ញើហាមឃាត់ | (1,302) | (1,624) | (1,974) |
| មូលធន និង ធនបំរុង | (17,905) | (22,862) | (26,759) |
| ផ្សេងៗ | (3,302) | (2,626) | (5,654) |
| **រូបិយវត្ថុទូទៅ (M2)** | **57,617** | **71,319** | **88,443** |
| រូបិយវត្ថុ (M1) | 7,273 | 9,428 | 10,227 |
| *រូបិយវត្ថុក្រៅធនាគារ* | *6,473* | *8,302* | *9,255* |
| *ប្រាក់បញ្ញើចរន្ត* | *800* | *1,127* | *972* |
| រូបិយវត្ថុផ្សេងៗ | 50,344 | 61,890 | 78,216 |
| *ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ* | *2,386* | *2,615* | *3,209* |
| *ប្រាក់បញ្ញើជារូបិយប័ណ្ណ (បរទេស)* | *47,957* | *59,275* | *75,008* |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.៦. វិស័យពាណិជ្ជកម្ម

*រូបភាព 5÷ បរិក្ខារសំណង់ ទោចក្រ-យានយន្ត និងវាយនភ័ណ្ឌនិងសម្លៀកបំពាក់ (គិតជាប៊ីលានរៀល)*




ប្រភពៈ ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង 8÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាប៊ីលានរៀល)*

| មុខទំនិញ | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| ថ្នាំពេទ្យ | 142 | 175 | 187 |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | 376 | 476 | 550 |
| ស្ករស និងប៊ីចេង | 56 | 41 | 38 |
| ប្រេងឆា និងអាហារផ្សេងៗ | 257 | 321 | 413 |
| សម្ភារសំណង់ | 541 | 612 | 1,021 |
| អេឡិចត្រូនិច | 6 | 8 | 125 |
| វាយនភ័ណ្ឌ | 3,660 | 3,801 | 3,969 |
| ទោចក្រ-យានយន្ត | 908 | 1,314 | 1,728 |
| គ្រឿងបន្លាស់យានយន្ត | 11 | 17 | 29 |
| បរិក្ខារត្រជាក់ | 77 | 69 | 77 |
| មាស | 707 | 346 | 342 |
| ប្រេងឥន្ធនៈ | 1,298 | 871 | 1,548 |
| ជីកសិកម្ម | 314 | 347 | 233 |
| ផ្សេងៗ | 4,135 | 5,424 | 6,762 |
| **សរុប** | **12,488** | **13,821** | **17,023** |

ប្រភពៈ ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រូបភាព 6÷ ស្ថានភាពមុខទំនិញនាំចេញសំខាន់ៗ (គិតជាប៊ីលានរៀល)




ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រូបភាព 7÷ ស្ថានភាពនាំចេញទៅទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)




ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *តារាង ៩÷ មុខទំនិញនាំចេញ (គិតជាប៊ីលានរៀល)*

| មុខទំនិញ | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| សម្លៀកបំពាក់ | 6,137 | 6,965 | 7,343 |
| ស្បែកជើង | 862 | 963 | 1,110 |
| វាយនភ័ណ្ឌផ្សេងៗ | 104 | 145 | 866 |
| គ្រឿងបង្គុំអេឡិចត្រូនិច | 0 | 391 | 147 |
| គ្រឿងបង្គុំរថយន្ត | 0 | 7 | 73 |
| កង់ | 0 | 423 | 411 |
| ឈើមូល | 0 | 15 | 129 |
| ឈើកែច្នៃ | 0 | 0 | 1 |
| ក្តារបន្ទះ | 0 | 0 | 17 |
| ផលិតផលផ្សេងៗពីឈើ | 68 | 132 | 8 |
| អង្ករ | 404 | 495 | 591 |
| ស្រូវ | 0 | 0 | 0 |
| កៅស៊ូ | 241 | 284 | 281 |
| ស្ករស | 0 | 32 | 40 |
| ផលិតផលជលផល | 1 | 1 | 0 |
| ផលិតផលកសិកម្មផ្សេងៗ | 7 | 38 | 55 |
| បារី | 20 | 21 | 24 |
| ខ្សែភ្លើង និងបង្គុំខ្សែភ្លើង | 0 | 0 | 164 |
| សំបកកំប៉ុង និងគម្របកំប៉ុង | 0 | 0 | 8 |
| មាស | 3 | 0 | 0 |
| ផលិតផលផ្សេងៗ | 2,069 | 1,719 | 1,269 |
| **នាំចេញសរុប** | **9,915** | **11,631** | **12,539** |

ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៧. ការវិនិយោគឯកជន

*តារាង 10÷ ស្ថិតិវិនិយោគវិស័យឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេស (អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាតវិនិយោគដោយ (CDC) | ឯកតា | ត្រីមាសទី៤ | | |
|---|---|---|---|---|
| | | ២០១៦ | ២០១៧ | ២០១៨ |
| **គម្រោង** | ចំនួន | 28 | 25 | 54 |
| **បង្កើតការងារ** | ការងារ | 26,692 | 21,220 | 45,940 |
| **ទុនវិនិយោគលើវិស័យ** | | | | |
| កសិកម្ម | លានដុល្លារ | 247 | 0 | 79 |
| ឧស្សាហកម្ម | លានដុល្លារ | 113 | 120 | 291 |
| សេវាកម្ម | លានដុល្លារ | 91 | 0 | 240 |
| ទេសចរណ៍ | លានដុល្លារ | 56 | 0 | 1,239 |
| **សរុប** | **លានដុល្លារ** | 507 | 120 | 1,850 |
| ទុនវិនិយោគក្នុងស្រុក | លានដុល្លារ | 51 | 6 | 718 |
| ទុនវិនិយោគបរទេស | លានដុល្លារ | 456 | 114 | 1,132 |

ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

*រូបភាព 8÷ ចំនួនគម្រោង និងទុនវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស (គិតជាលានដុល្លារអាមេរិក)*




ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ២.៨. វិស័យទេសចរណ៍

*តារាង 11 ÷ ចំនួនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា*

| សូចនាករ | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ (*) |
| **សរុប** | **1,503,297** | **1,689,396** | **1,792,981** |
| តាមផ្លូវអាកាស | 797,391 | 929,329 | 1,136,316 |
| ភ្នំពេញ | 330,054 | 383,113 | 520,057 |
| សៀមរាប | 449,574 | 522,336 | 517,097 |
| កងកេង | 17,763 | 23,880 | 99,162 |
| តាមផ្លូវគោក និង ផ្លូវទឹក | 705,906 | 760,067 | 656,665 |
| ផ្លូវគោក | 667,901 | 722,926 | 610,347 |
| ផ្លូវទឹក | 38,005 | 37,141 | 46,318 |

ប្រភព: ក្រសួងទេសចរណ៍

(*) ធ្វើចំណោលទិន្នន័យខែធ្នូ សម្រាប់ប៉ាន់ស្មានចំនួនភ្ញៀវក្នុងត្រីមាសទី៤។ ទិន្នន័យនេះ នឹងកែសម្រួលឡើងវិញក្នុងត្រីមាសទី១ឆ្នាំ២០១៩

*រូបភាព 9 ÷ កំណើនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា (គិតជា %)*




ប្រភព: ក្រសួងទេសចរណ៍

## ២.៩. វិស័យសំណង់

*តារាង 12 ÷ គម្រោងអនុញ្ញាតសាងសង់*

| | ឯកត្តា | ត្រីមាសទី៤ | | |
|---|---|---|---|---|
| | | ២០១៦ | ២០១៧ | ២០១៨ |
| **សំណើសុំសាងសង់** | | | | |
| គម្រោង | ចំនួន | 627 | 896 | 749 |
| តម្លៃសាងសង់ | លានដុល្លារ | 974 | 1,163 | 935 |
| **សំណើសុំសាងសង់តាមប្រភេទ** | | | | |
| សំណង់សាធារណៈ | ម២ | 9,079 | 28,217 | 3,893 |
| លំនៅដ្ឋាន និងភូមិគ្រឹះ | ម២ | 1,600,050 | 873,178 | 906,946 |
| សំណង់ឧស្សាហកម្ម | ម២ | 575,213 | 373,963 | 114,302 |
| សំណង់ពាណិជ្ជកម្ម | ម២ | 153,044 | 884,234 | 481,075 |
| សំណង់ទេសចរណ៍ | ម២ | 12,656 | 77,814 | 80,141 |
| សំណង់វិនិយោគផ្សេងៗ | ម២ | 777 | 933 | 288 |
| **សរុប** | **ម២** | **2,350,819** | **2,238,338** | **1,586,643** |

ប្រភព: ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់

*រូបភាព 10 ÷ សំណើសុំវិនិយោគសាងសង់ គិតជាក្រឡាផ្ទៃ ចែកតាមប្រភេទសំណង់*




ប្រភព: ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់

# ៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

*តារាង 13 ÷ ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក)*

| មុខទំនិញ | ឯកតា | ទីផ្សារ | ត្រីមាសទី៤ | | |
|---|---|---|---|---|---|
| | | | ២០១៦ | ២០១៧ | ២០១៨ |
| អង្ករ | តោន/ ដុល្លារ | បាងកក | 340 | 379 | 401 |
| ប្រេងឆៅ Brent | ធុង/ ដុល្លារ | ក្រុងឡុង | 46 | 63 | 65 |
| កៅស៊ូ | តោន/ ដុល្លារ | សឹង្ហបុរី | 1,871 | 1,569 | 1,353 |
| មាស | អោន/ ដុល្លារ | ហុងកុង | 1,359 | 1,406 | 1,339 |
| ពោតក្រហម | តោន/ ដុល្លារ | ស៊ីកាហ្គោ | 152 | 149 | 161 |
| សណ្តែកសៀង | តោន/ ដុល្លារ | ស៊ីកាហ្គោ | 409 | 401 | 374 |
| ប្រេងដូង | តោន/ ដុល្លារ | រ៉ុតធើឌាំ | 1,524 | 1,549 | 787 |
| ស្ករស | តោន/ ដុល្លារ | ក្រុងឡុង | 353 | 383 | 371 |

ប្រភព: គេហទំព័រធនាគារពិភពលោក

*រូបភាព 11 ÷ ថ្លៃជីកសិកម្មលើទីផ្សារអន្តរជាតិសម្រាប់ត្រីមាសទី៤ (គិតជាដុល្លារអាមេរិក/ម៉ែត្រទ្រីកតោន)*




ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*តារាង 14 ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ឆ្នាំគោល ២០១០=១០០)*

| មុខទំនិញ | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| ប្រេងឥន្ធនៈ | 45 | 60 | 62 |
| ផលិតផលកសិកម្ម | 90 | 87 | 82 |
| ម្ហូបអាហារ | 93 | 92 | 85 |
| ឈើ | 84 | 87 | 85 |
| ជីគីមី | 73 | 75 | 93 |

ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*រូបភាព 12 ÷ សន្ទស្សន៍ថ្លៃមុខទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិសម្រាប់ត្រីមាសទី៤*




ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*តារាង 15 ÷ អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិធៀបនឹងដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*

| រូបិយប័ណ្ណ | ត្រីមាសទី៤ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| ជប៉ុន (យ៉េន) | 116.72 | 112.65 | 110.24 |
| ហុងកុង (ដុល្លារ) | 7.75 | 7.81 | 7.83 |
| សឹង្ហបុរី (ដុល្លារ) | 1.45 | 1.34 | 1.37 |
| ម៉ាឡេស៊ី (រីងហ្គីត) | 4.48 | 4.06 | 4.15 |
| ហ្វីលីពីន (ប៉េសូ) | 49.48 | 49.90 | 52.56 |
| ថៃ (បាត) | 35.76 | 32.55 | 32.40 |
| ឥណ្ឌូនេស៊ី (រូពា) | 13,440.90 | 13,544.40 | 14,555.80 |
| កូរ៉េ (វ៉ុន) | 1,203.51 | 1,066.24 | 1,115.57 |
| តៃវ៉ាន់ (ដុល្លារ) | 32.32 | 29.66 | 30.56 |
| ចិន (រ៉េនមីនប៊ី) | 6.95 | 6.52 | 6.88 |
| ឡាវ (គីប) | 3,928.39 | 4,008.68 | 3,999.88 |
| វៀតណាម (ដុង) | 7,908.57 | 8,238.79 | 8,532.48 |
| ឥណ្ឌា (រូពី) | 22,437.90 | 22,640.30 | 23,187.00 |
| រុស្សី (រូប) | 67.84 | 63.71 | 69.48 |
| អូស្ត្រាលី (ដុល្លារ) | 60.80 | 57.61 | 69.35 |
| អង់គ្លេស (ផោន) | 1.38 | 1.28 | 1.42 |
| អឺរ៉ុប (អឺរ៉ូ) | 0.81 | 0.74 | 0.79 |

ប្រភព: OANDA (Internet)

# ឧបសម្ព័ន្ធ

*តារាង 16÷ ស្ថិតិកសិកម្ម*

| ផលិតកម្មកសិកម្ម និងនាំចេញ | ឯកតា | ត្រីមាសទី៤ | | |
|---|---|---|---|---|
| | | ២០១៦ | ២០១៧ | ២០១៨ |
| ផ្ទៃដីដាំដុះ | | | | |
| ស្រូវ | ហិកតា | 2,907,087 | 2,989,631 | 3,209,585 |
| ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម | ហិកតា | 963,001 | 953,053 | 1,021,636 |
| កៅស៊ូ | ហិកតា | 431,053 | 436,338 | 436,682 |
| ផ្ទៃដីប្រមូលផល | | | | |
| ស្រូវ | ហិកតា | 2,315,794 | 2,382,929 | 2,420,376 |
| កៅស៊ូ | ហិកតា | 126,996 | 170,232 | 201,950 |
| បរិមាណផល | | | | |
| ស្រូវ | តោន | 6,857,807 | 7,184,906 | 7,435,246 |
| កៅស៊ូ (ក្រែប) | តោន | 127,852 | 193,285 | 220,100 |
| ជលផល | តោន | 802,450 | 856,263 | 910,153 |
| នាំចេញ | | | | |
| អង្ករ | តោន | 525,829 | 573,441 | 577,299 (*) |
| កៅស៊ូ | តោន | 125,962 | 157,304 | 164,800 |
| ស្ករ | តោន | 0 | 130,001 | 335,202 |
| ផលិតផលជលផល | តោន | 214 | 340 | 1,873 |
| ផលិតផលកសិកម្មផ្សេងៗ | តោន | 88,190 | 218,641 | 312,523 |

ប្រភពៈ របាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
របាយការណ៍ពាណិជ្ជកម្មប្រចាំខែ

*សម្គាល់÷ (*) ស្ថិតិនាំចេញពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ ប៉ុន្តែស្ថិតិនៃការនាំចេញអង្ករពីកម្ពុជាទៅទីផ្សារអន្តរជាតិ កត់ត្រាតាមរយៈលេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ សម្រាប់ឆ្នាំ២០១៨ មានរហូតដល់ ៦២៦.២២៥ តោន ។*

*រៀបចំដោយនាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច នៃអគ្គនាយកដ្ឋានគោលនយោបាយ*

*ទំនាក់ទំនងៈ (855) 12 997 616*

*(855) 89 898 878*

*Email: sead@mef.gov.kh*